មេរៀនទី ៣

# យ៉ូហានជំពូកទី ៥-៧

John 5-7

## គម្រោង

ក. ការប្រោសឱ្យជានៅស្រះទឹក The Healing at the Pool

ខ. អំណាចរបស់ព្រះបុត្រា The Authority of the Son

គ. ការអស្ចារ្យបន្ថែមទៀតរបស់ព្រះយេស៊ូ More Miracles of Jesus

ឃ. មនុស្សស្វែងនំប៉័ងផ្តល់ជីវិត The People Seek the Bread of Life

ង. ព្រះបន្ទូលផ្តល់ជីវិតអស់កល្បជានិច្ច The Words of Eternal Life

ច. ព្រះយេស៊ូ និងព្រះញាតិវង្សរបស់ព្រះអង្គ Jesus and His Brothers

ឆ. នៅពិធីបុណ្យបារាំ At the Feast of Tabernacles

ជ. តើលោកនេះគឺជាព្រះមេស្ស៊ី? Is He the Messiah?

ឈ. ការខ្វែងគំនិតរបស់បណ្តាជន Division Among the People

## គោលដៅ

១. លើកពីចំណុចសំខាន់នៃការប្រោសឱ្យជារបស់ព្រះយេស៊ូចំពោះបុរសម្នាក់នៅឯស្រះ។

២. ទឹកពិពណ៌នាអំពីអំណាចដែលព្រះបិតាបានប្រទានឱ្យព្រះត្រា។

៣. ពិភាក្សាពីមេរៀននៃការប្រទានអាហារដល់មនុស្សប្រាំពាន់នាក់ និងពន្យល់ពីរបៀបដែលព្រះយេស៊ូដើរលើទឹកបង្ហាញពីភាពជាព្រះរបស់ព្រះអង្គ។

៤. ពន្យល់ពីអត្ថន័យដែលព្រះយេស៊ូពិពណ៌នាថាអង្គទ្រង់ផ្ទាល់ជានំប៉័ងជីវិត។

៥. លើកបង្ហាញពីអ្វីដែលមនុស្សត្រូវធ្វើដើម្បីបានជីវិតអស់កល្បជានិច្ច។

៦. ពន្យល់ពីសារៈសំខាន់នៃការអត់ធ្មត់ក្នុងការដោះស្រាយជាមួយអ្នកដែលមិនជឿ។

៧. ពិពណ៌នាពីអាកប្បកិរិយាបីសំដៅទៅរកព្រះយេស៊ូ និងពន្យល់ពីសេចក្តីបង្រៀនរបស់ព្រះយេស៊ូនៅក្នុងពិធីបុណ្យ។

៨. ពន្យល់ពីហេតុផលដែលព្រះយេស៊ូនៅតែបន្តព័ន្ធកិច្ចរបស់ព្រះអង្គ ទោះបីជាព្រះអង្គមានសត្រូវក៏ដោយ។

៩. កំណត់ពីរបៀបដែលព្រះយេស៊ូបានបំពេញតាមទំនាយអំពីព្រះមេស្ស៊ី។

## ក. ការប្រោសឱ្យជានៅស្រះទឹក The Healing at the Pool

**គោលដៅទី១. លើកពីចំណុចសំខាន់នៃការប្រោសឱ្យជារបស់ព្រះយេស៊ូចំពោះបុរសម្នាក់នៅឯស្រះទឹក។**

សូមអានយ៉ូហាន ៥:១-១៨។ជំពូកទី៥បាននិយាយអំពីបុរសម្នាក់ដែលពិការអស់រយៈពេល៣៨ឆ្នាំមកហើយ ប៉ុន្តែជាមនុស្សម្នាក់ដែលតែងតែមានសង្ឃឹមយ៉ាងមុតមាំថាគាត់នឹងបានជា។ នៅទីកន្លែងនោះមានស្រះទឹកមួយដែលមនុស្សអាចនឹងទទួលបានការប្រោសឱ្យជាប្រសិនបើពេលណាទេវតាធ្វើឱ្យទឹកនោះកំរើកមានតែអ្នកដែលបានចូលទៅក្នុងស្រះទឹកនោះមុនគេប៉ុណ្ណោះទើបបានជាសះស្បើយ។ បុរសម្នាក់នោះគឺមិនដែលទៅទាន់ទឹកនោះកំរើកឡើយដូច្នេះគាត់មិនទទួលបានការប្រោសឱ្យជាទេ។ប៉ុន្តែបន្ទាប់ពីព្រះយេស៊ូមានព្រះបន្ទូលមកកាន់គាត់ទ្រង់ក៏បានប្រោសគាត់ឱ្យជា។ មានអ្នកដឹកនាំសាសនាមួយចំនួនមានការខឹងនឹងព្រះយេស៊ូជាខ្លាំងដោយសារតែទ្រង់ប្រោសបុរសម្នាក់នោះឱ្យបានជានៅក្នុងថ្ងៃសប្ប័ទ។

ពួកគេចាត់ទុកថ្ងៃសប្ប័ទជាថ្ងៃសម្រាប់ថ្វាយបង្គំហើយមិនត្រូវឱ្យនរណាម្នាក់ធ្វើការនៅក្នុងថ្ងៃនោះឡើយ។ ពួកមេដឹកនាំទាំងនោះព្រួយបារម្ភពីបុរសពិការនោះបានធ្វើល្មើសនឹងច្បាប់នៅក្នុងសាសនារបស់គេជាជាងការអស្ចារ្យដែលព្រះយេស៊ូបានធ្វើដើម្បីផ្លាស់ប្តូរជីវិតរបស់បុរសពិកានោះទៅទៀត។ពួកគេគិតពីប្រពៃណីរបស់ពួកគេជាជាងតម្រូវការរបស់បុរសនោះ។វាជាការពិតណាស់ដែលមានពេលមួយថ្ងៃនៅក្នុងមួយសប្តាហ៍ញែកដាច់សម្រាប់ថ្វាយបង្គំ ប៉ុន្តែ វាជាការគិតមួយដ៏ឆ្លាតប្រសិនបើយើងយកថ្ងៃនោះទៅជួយដល់មនុស្សដែលកំពុងតែត្រូវការជំនួយ។

**លំហាត់អនុវត្តន៍**

---

១ ហេតុអ្វីបានជាបុរសពិការនោះរង់ចាំនៅមាត់ស្រះបេថែសដា?

ក) គាត់ចង់ផឹកទឹក។

ខ) គាត់ចង់ប្រោសឱ្យជា។

គ) គាត់ចង់ងូតទឹក។

២ ពួកមេដឹកនាំសាសនាខឹងដោយសារ

ក) ពួកគេមិនបានទទួលប្រាក់ពីការប្រោសឱ្យជានោះ។

ខ) ការប្រោសឱ្យជាមិនមែនមកពីគ្រូពេទ្យ។

គ) ព្រះយេស៊ូបានប្រោសបុរសពិកានៅក្នុងថ្ងៃសប្ប័ទ។

## ខ.អំណាចរបស់ព្រះបុត្រា The Authority of the Son

**គោលដៅទី២. ពន្យល់ពីរបៀបដែលព្រះយេស៊ូបានប្រោសកូននាយទាហានបានបង្ហាញភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូ។**

សូមអានយ៉ូហាន ៥:១៩-២៩។ ព្រះជាម្ចាស់បានប្រទានអំណាចទៅព្រះបុត្រារបស់ព្រះអង្គ ព្រះយេស៊ូ និងសិទ្ធក្នុងការប្រោសឱ្យជា ប្រោសមនុស្សពីស្លាប់ឱ្យរស់ឡើងវិញ អត់ទោសអំពើបាប និងសូម្បីតែវិនិច្ឆ័យទោសពិភពលោក។ នៅក្នុងខទី២៤ បានផ្តល់នូវសេចក្តីសន្យាទៅអស់អ្នកដែលបានឮព្រះបន្ទូលរបស់ព្រះយេស៊ូ ហើយជឿលើព្រះអង្គ និងមិនត្រូវទទួលទោសដោយព្រោះតែអំពើបាបរបស់គេឡើយ។ ពួកគេត្រូវបានអត់ទោស និងទទួលបានជីវិតអស់កល្បជានិច្ច (យ៉ូហាន ១៧:៣)។ ពួកគេមិនចាំបាច់ទទួលទោសនៅចំពោះព្រះភ័ក្ររបស់ព្រះយេស៊ូឡើយ ដោយសារតែពួកគេបានជឿទៅលើទ្រង់ជាព្រះសង្គ្រោះ។

**លំហាត់អនុវត្តន៍**

---

៣ ខគម្ពីរចងចាំ យ៉ូហាន ៥:២៤។

៤ តើនរណាដែលនឹងមិនត្រូវទទួលការវិនិឆ្ឆ័យទោសពីព្រះយេស៊ូដោយព្រោះអំពើបាបរបស់គេ?
ក) អស់អ្នកដែលជាសមាជិកក្រុមជំនុំ
ខ) អស់អ្នកដែលមិនដែលធ្វើអំពើបាបសោះ
គ) អស់អ្នកដែលបានឮព្រះបន្ទូលរបស់ព្រះយេស៊ូ ហើយបានជឿទៅលើព្រះអង្គ និងព្រះជាម្ចាស់

## សាក្សីអំពីព្រះយេស៊ូ Witnesses to Jesus

សូមអាន យ៉ូហាន ៥:៣០-៤៧ បាននិយាយពីបន្ទាល់អំពីព្រះយេស៊ូ។ សាក្សីអំពីព្រះយេស៊ូគឺជាអស់អ្នក ឬ អ្វីមួយដែលនិយាយអំពីព្រះយេស៊ូ និងប្រកាសភាពជាព្រះរបស់ព្រះអង្គ។ ទីបន្ទាល់ទាំងអស់នៅក្នុងជំពូកនេះជាភស្តុតាងថាព្រះយេស៊ូគឺជាព្រះបុត្រារបស់ព្រះជាម្ចាស់។

លោក យ៉ូហានបាទីស្តគឺជាម្នាក់នៅក្នុងចំណោមសាក្សីទាំងនោះ (ខ៣៣)។ កិច្ចការដែលព្រះយេស៊ូបានធ្វើជាបន្ទាល់របស់ព្រះអង្គ (ខ៣៦) ផ្តល់ភស្តុតាងថាទ្រង់គឺជាបុត្រារបស់ព្រះជាម្ចាស់។ ព្រះបិតាក៏បានផ្តល់បន្ទាល់ផងដែរ (ខ៣៧)។ បន្ទាប់មកការសសេរព្រះបន្ទូលរបស់ព្រះជាម្ចាស់បានក្លាយជាទីបន្ទាល់ (ខ៣៩) ព្រះយេស៊ូមិនគ្រាន់តែជាមនុស្សធម្មតានោះទេ។ ទ្រង់គឺជាម្នាក់ដែលត្រូវបានព្រះបិតាបញ្ជូនឱ្យមកដើម្បីប្រទានការសង្គ្រោះ និងជីវិតអស់កល្ប។

## គ. ការអស្ចារ្យបន្ថែមទៀតរបស់ព្រះយេស៊ូ More Miracles of Jesus

គោលដៅទី៣. ពិភាក្សាពីមេរៀននៃការប្រទានអាហារដល់មនុស្សប្រាំពាន់នាក់ និងពន្យល់ពីរបៀបដែលព្រះយេស៊ូដើរលើទឹកបង្ហាញពីភាពជាព្រះរបស់ព្រះអង្គ។

### ព្រះយេស៊ូប្រទាននំប៉័ងអោយមនុស្សប្រាំពាន់នាក់ Jesus Feeds the Five Thousand

សូមអាន យ៉ូហាន ៦:១-១៥។ លោក ម៉ាថាយ ជាសិស្សម្នាក់ទៀតរបស់ព្រះយេស៊ូបានប្រាប់យើងជាច្រើនបន្ថែមទៀតអំពីការអស្ចារ្យនេះនៅក្នុងជំពូកទី១៤នៃដំណឹងល្អរបស់គាត់។ ព្រះយេស៊ូ និងសិស្សរបស់ព្រះអង្គបានចេញទៅកន្លែងដែលឆ្ងាយពីហ្វូងមនុស្ស។ ប៉ុន្តែ ហ្វូងមនុស្សបានដើរតាមព្រះអង្គបាននាំអ្នកជំងឺមកជាមួយដើម្បីឱ្យព្រះយេស៊ូប្រោសពួកគេ។ ហើយព្រះយេស៊ូក៏បានប្រោសពួកគេ ទ្រង់មានព្រះហឫទ័យអាណិតអាសូរដល់ពួកគេ។ វាជិតយឺតពេលទៅហើយ មនុស្សទាំងអស់ឃ្លាន ហើយនៅទីនោះពុំមានកន្លែងទិញអាហារសម្រាប់បរិភោគនោះទេ។ ព្រះយេស៊ូបានបង្រៀនពួកគេពីមេរៀនជាច្រើន តាមរយៈអ្វីដែលទ្រង់នឹងធ្វើបន្ទាប់ទៀតនេះគឺបញ្ជាក់ថាទ្រង់អាចបំពេញសេចក្តីត្រូវការរបស់យើង។

ការបកប្រែពាក្យ ״ដុំ (នំប៉័ង)״ មានន័យថាជាចំនិតនំប៉័ងតូចៗ ឬនំផ្អែម។ ជំនិតនំប៉័ងប្រាំដុំ និងត្រីតូចពីរកន្ទុយគឺជាអាហារពេលថ្ងៃត្រង់ដ៏ឈ្ងុយឆ្ងាញ់របស់ក្មេងប្រុសដែលកំពុងតែឃ្លាន។ នៅពេលដែលព្រះយេស៊ូសុំនំប៉័ង និងត្រី ក្មេងប្រុសម្នាក់នោះបានឱ្យអាហារថ្ងៃត្រង់ទៅព្រះអង្គ។ ជាមួយព្រះពររបស់ព្រះយេស៊ូសម្រាប់អាហារពេលថ្ងៃត្រង់នេះបានធ្វើឱ្យមនុស្សប្រាំពាន់នាក់បានបរិភោគឆ្អែតទាំងអស់គ្នា។ យើងនឹងមិនខាតបង់នោះទេនៅពេលដែលយើងឱ្យអ្វីទៅព្រះជាម្ចាស់នូវអ្វីដែលយើងមាន។ ទ្រង់តែងតែសងមកយើងវិញច្រើនជាងអ្វីដែលយើងបានឱ្យទៅព្រះអង្គទៅទៀត។

វាបានកើតឡើងនៅពេលដែលព្រះយេស៊ូបានអរព្រះគុណព្រះជាម្ចាស់នូវអ្វីដែលទ្រង់មាន ហើយពេលនោះក៏មានអាហារយ៉ាងច្រើនសន្ធឹកសន្ធាប់។ ក៏ដូចជាពេលដែលយើងអរព្រះគុណដល់ព្រះជាម្ចាស់នូវអ្វីដែលទ្រង់បានប្រទានដល់យើងដែរ នោះទ្រង់នឹងបំពេញតាមសេចក្តីត្រូវការរបស់យើង។ សាវ័ករបស់ព្រះអង្គក៏បានជួយនៅក្នុងការអស្ចារ្យនេះផងដែរ។ នៅពេលដែលពួកគេទទួលយកម្ហូបពីព្រះហស្ត របស់ព្រះយេស៊ូម្ហូបអាហារនោះបានកើនឡើងទ្វេដងដើម្បីបំពេញតម្រូវការរបស់ពួកគេ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានពេលខ្លះត្រូវបានហៅថា នំប៉័ង និងសាច់។ នៅពេលដែលយើងចែកចាយព្រះបន្ទូលរបស់ព្រះអង្គជាមួយអ្នកដទៃ ព្រះជាម្ចាស់នឹងប្រទានពរ ហើយប្រើព្រះបន្ទូលដើម្បីបំពេញដល់ព្រលឹងវិញ្ញាណដែលស្រេកឃ្លាន។

ព្រះយេស៊ូតែងតែធ្វើតាមរបៀបដដែល។ ទ្រង់រៀបចំគ្រប់យ៉ាងបានយ៉ាងល្អ ដូច្នេះទើបបណ្តាជនអាចបរិភោគអាហារបានគ្រប់គ្រាន់ដោយគ្មានការយល់ច្រឡំ។ បន្ទាប់មកទ្រង់បានប្រាប់ឱ្យពួកសាវ័កប្រមូលអ្វីដែលនៅសល់ ដូចជាបង្រៀនដល់ពួកគេកុំឱ្យខ្ជះខ្ជាយ។

បណ្ដាជនមានការភ្ញាក់ផ្អើលជាមួយការអស្ចារ្យមួយនេះ។ ព្រះមេស្ស៊ីដែលព្រះជាម្ចាស់បានសន្យានឹងក្លាយជាព្យាការីដូចជាលោកម៉ូសេ។ លោក ម៉ូសេបានអធិស្ឋាន ហើយព្រះជាម្ចាស់បានប្រទានអាហារដល់ប្រជាជន គឺនំម៉ាណានៅវាលរហោស្ថាន។ព្រះយេស៊ូដូចគ្នា បានធ្វើការអស្ចារ្យដោយបានចម្អែតហ្វូងមនុស្សដូចជាពេលដែលព្រះជាម្ចាស់បានធ្វើសម្រាប់ហ្វូងមនុស្សនៅវាលរហោស្ថានដែរ។ ព្រះមេស្ស៊ីគួរតែជាព្យាការី។ ពួកគេចង់ឱ្យព្រះអង្គធ្វើជាព្រះមហាក្សត្រ។

ប៉ុន្តែ ព្រះយេស៊ូមិនបានយាងមកទំលាក់អំណាចគ្រប់គ្រងរបស់ចក្រភពរ៉ូម ហើយក្លាយជាអ្នកដែលកាន់អំណាចនៅក្នុងប្រទេសនោះទេ។ ទ្រង់យាងមកដើម្បីផ្ដួលរលំអំណាចរបស់អំពើបាប និងសេចក្ដីងងឹត។ ទ្រង់អាចនឹងក្លាយជាព្រះអម្ចាស់ និងជាស្ដេចនៅលើជីវិតទាំងអស់ ប៉ុន្តែ អាណាចក្ររបស់ព្រះអង្គជាវិញ្ញាណ មិនមែនខាងនយោបាយនោះទេ។ មនុស្សមិនអាចយល់ពីសេចក្ដីនេះឡើយ ដូច្នេះទ្រង់ក៏បានចាកចេញទៅកន្លែងផ្សេងទៀត។

### លំហាត់អនុវត្តន៍

---

៥ តើអ្នកបានអធិស្ឋានអរគុណព្រះជាម្ចាស់សម្រាប់អាហាររបស់អ្នកមុនពេលទទួលទានដែលឬទេ?

.......................................................................................................................................................

៦ តើការអស្ចារ្យអ្វីដែលព្រះជាម្ចាស់បានធ្វើជាមួយនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយរបស់ក្មេងប្រុសនោះ?

ក) ទ្រង់បានធ្វើឱ្យមានអាហារគ្រប់គ្រាន់សម្រាប់សាវ័កទាំងដប់ពីរបរិភោគ។

ខ) ទ្រង់បានធ្វើឱ្យកន្ត្រក់អាហារទាំងដប់ពីរពេញទាំងអស់។

គ) ទ្រង់បានធ្វើឱ្យមានអាហារបរិភោគគ្រប់គ្រាន់សម្រាប់មនុស្សប្រាំពាន់នាក់។

៧ បន្ទាប់ពីព្រះយេស៊ូបានចម្អែតពួកគេហើយ បណ្ដាលជនចង់

ក) សារភាពអំពើបាបរបស់ពួកគេ ហើយទទួលការសង្គ្រោះ។

ខ) អភិសេកព្រះយេស៊ូជាស្ដេចនៅលើប្រទេសរបស់ពួកគេ។

គ) ទទួលព្រះយេស៊ូជាអ្នកដឹកនាំខាងឯព្រលឹងវិញ្ញាណ។

## ព្រះយេស៊ូយាងលើទឹកសមុទ្រ Jesus Walks on Water

សូមអាន យ៉ូហាន ៦:១៦-២១។ ត្រឡប់មកវិញទៅឆ្លងបឹងកាលីឡេ ពួកសាវ័កមានការភ័យខ្លាច ពីព្រោះព្យុះធំនឹងធ្វើឱ្យលិចទូករបស់ពួកគេ។ ព្រះយេស៊ូបានយាងលើទឹក និងបានយាងចូលទៅក្នុងទូកហើយសង្គ្រោះពួកគេ។ តើមាននរណាទៀតដែលអាចដើរលើទឹក និងបញ្ឈប់ខ្យល់ព្យុះ? គ្មាននរណាទៀតឡើយ គឺមានតែព្រះយេស៊ូមួយប៉ុណ្ណោះ! ព្រះយេស៊ូអាចធ្វើគ្រប់កិច្ចការទាំងអស់ពីព្រោះតែទ្រង់ជាព្រះបុត្រារបស់ព្រះជាម្ចាស់។

វត្តមានរបស់ព្រះយេស៊ូនៅក្នុងទូកប្រៀបធៀបពីវត្តមានរបស់ព្រះអង្គនៅក្នុងជីវិតយើងទាំងអស់គ្នា។ ស្ថិតនៅជាមួយព្រះអង្គគឺយើងមានសុវត្ថិភាពនៅក្នុងព្យុះនៃបញ្ហា។ ទ្រង់នឹងយកសេចក្តីភ័យខ្លាចចេញ ហើយប្រទានឱ្យយើងនូវសេចក្តីសុខសាន្ត។ ដាវីឌ ជាស្តេចអ៊ីស្រាអែលនៅក្នុងព្រះគម្ពីរបានសរសេរថា "មនុស្សទុគ៌តស្រែកអង្វរព្រះអម្ចាស់ព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យគេហើយសង្គ្រោះគេអោយរួចផុតពីគ្រោះកាចទាំងប៉ុន្មានផង" (ទំនុកតម្កើង ៣៤:៦)

លំហាត់អនុវត្តន៍

---

៨ តើព្រះអម្ចាស់ធ្លាប់បានដកសេចក្តីភ័យខ្លាចចេញពីអ្នក ហើយប្រទានសេចក្តីសុខសាន្ត ឬក៏បានរំដោះអ្នកចេញពីបញ្ហាដែរឬទេ? អរព្រះគុណព្រះអង្គសម្រាប់ការនេះ។

## ឃ. មនុស្សស្វែងរកនំបុ័ងជីវិត The People Seek the Bread of Life

គោលដៅទី៤. ពន្យល់ពីអត្ថន័យដែលព្រះយេស៊ូពិពណ៌នាថាអង្គទ្រង់ផ្ទាល់ជានំបុ័ងជីវិត។

សូមអាន យ៉ូហាន ៦:២២-៥៩។ ព្រះយេស៊ូមានភាពល្បីល្បាយ ហើយមានបណ្តាជនបានដើរតាមព្រះអង្គគ្រប់ទីកន្លែងដែលទ្រង់ យាងទៅ។ ពួកគេបានគិតថា ប្រហែលទ្រង់ជាមនុស្សតែម្នាក់គត់ដែលពួកគេត្រូវការសម្រាប់អភិសេកធ្វើជាស្តេច។ ជាមួយនឹងអំណាចដ៏អស្ចារ្យរបស់ព្រះអង្គ ទ្រង់អាចប្រោសមនុស្សទាំងអស់ឱ្យបានជា ទំនុកបំរុងអាហារដល់ពួកគេ ហើយពួកគេនឹងមិនចាំបាច់ធ្វើការអ្វីឡើយ។

នៅក្នុងពេលនោះ ផ្ទះរបស់ព្រះយេស៊ូគឺ នៅក្នុងទីក្រុង កាពើណិម នៅត្រើយខាងលិចនៃឆ្នេរសមុទ្រនៃស្រុកកាលីឡេ។ ក្រុមមនុស្សដែលចង់ឱ្យព្រះអង្គក្លាយជាមេដឹកនាំនៅក្នុងចលនាបដិវត្តន៍បានដើរតាមព្រះអង្គមកដល់កន្លែងនោះដែរ។ ប៉ុន្តែព្រះយេស៊ូមិនបានបំពេញតាមការចង់បានរបស់ពួកគេទេ។ក្រោយមកសត្រូវរបស់ព្រះអង្គបានព្យាយាមចោទប្រកាន់ព្រះអង្គដើម្បីធ្វើឱ្យមានការចលាចលដល់ការបដិវត្តន៍ ប៉ុន្តែមនុស្សបានដឹងថាការធ្វើដ៏ល្ងង់ខ្លៅមួយនេះនឹងសងដល់ពួកគេវិញ។

លំហាត់អនុវត្តន៍

---

៩ ហ្វូងបណ្តាជនបានដើរតាមព្រះយេស៊ូរហូតដល់ផ្ទះរបស់ព្រះអង្គនៅ

ក) ក្រុងកាពើណិម នៅលើសមុទ្រ មេឌីទែរ៉ាន់។

ខ) ក្រុងកាពើណិម នៃឆ្នេរសមុទ្រនៃស្រុកកាឡីលេ។

គ) ស្រុកណាសារ៉ែត។

ព្រះយេស៊ូបានបង្រៀនថាព្រះជាម្ចាស់ចង់ឱ្យមនុស្សទាំងអស់ទទួលជឿលើព្រះអង្គ។ ទោះបីជា បណ្តាជនគ្រាន់តែចង់ឱ្យព្រះយេស៊ូប្រទាននំម៉ាណាដល់ពួកគេក៏ដោយ តែទ្រង់ចង់ឱ្យពួកគេដឹងថាទ្រង់មានអ្វីដែលប្រសើរជាងនេះនៅក្នុងព្រះតម្រិះរបស់ព្រះអង្គ។ ទ្រង់គឺជានំបុ័ងជីវិតដែលព្រះជាម្ចាស់បានបញ្ជូនមកពីនគរស្ថានសួគ៌។

មានមនុស្សមួយចំនួនមិនយល់ពីអត្ថន័យដែលព្រះយេស៊ូមានព្រះបន្ទូលថា ពួកគេត្រូវតែបរិភោគសាច់ និងផឹកឈាមរបស់ព្រះអង្គ។ នេះគឺជាគំរូឧទាហរណ៍នៅក្នុងន័យប្រៀបធៀបផ្សេងទៀត។ អត្ថន័យរបស់ព្រះយេស៊ូគឺថាមនុស្សទាំងអស់ត្រូវតែទទួលយកព្រះយេស៊ូដាក់ក្នុងជីវិតរបស់ពួកគេ ដូចជាពួកគេបរិភោគម្ហូបអាហារចិញ្ចឹមរូបកាយគេដែរ។ ម្ហូបអាហារចិញ្ចឹមជីវិតផ្នែកខាងសាច់ឈាមរបស់គេ។ តែទ្រង់នឹងប្រទានឱ្យពួកគេនូវជីវិតអស់កល្បជានិច្ច។

អស់រយៈពេលក្រោយមក ព្រះយេស៊ូបានប្រទាននំបុ័ង និងស្រាព្រមទាំងមានព្រះបន្ទូលប្រាប់ពួកគេថានេះជាតំណាងរូបកាយនិងព្រះលោហិតរបស់ព្រះអង្គ។ ទ្រង់បានប្រាប់ពួកគេឱ្យចងចាំការសុគតរបស់ព្រះអង្គគ្រប់ពេលដែលពួកបរិភោគជាមួយគ្នានៅក្នុងរបៀបនេះ។ ដូច្នេះហើយបានសព្វថ្ងៃពួកយើងមានពិធីសម្ពន្ធភាពវិសុទ្ធ ឬ ពិធីលៀងព្រះអម្ចាស់ដែលទទួលស្គាល់ការចងចាំមួយនេះ។

**លំហាត់អនុវត្តន៍**

---

១០ ចងចាំខគម្ពីរ យ៉ូហាន ៦:២៩។

១១ តើព្រះយេស៊ូចង់មានន័យយ៉ាងណានៅពេលដែលព្រះអង្គមានព្រះបន្ទូលថា "ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថាប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្ស*ទេ អ្នករាល់គ្នាគ្មានជីវិតក្នុងខ្លួនឡើយ"
- ក) មនុស្សទាំងអស់ត្រូវតែបរិភោគសាច់ឈាមរបស់ព្រះអង្គ។
- ខ) មនុស្សទាំងអស់ត្រូវតែផឹកលោហិតរបស់ព្រះអង្គ។
- គ) មនុស្សទាំងអស់ត្រូវតែទទួលយកព្រះអង្គមកដាក់នៅក្នុងជីវិតរបស់ពួកគេដូចជាគេបរិភោគអាហារសម្រាប់បំពេញរូបកាយរបស់គេដែរ។

១២ គោលបំណងនៃពិធីលៀងព្រះអម្ចាស់គឺ
- ក) សង្គ្រោះយើងពីអំពើបាប។
- ខ) បង្ហាញថាយើងជាសមាជិកនៅក្នុងក្រុមជំនុំ។
- គ) តំណាងឱ្យព្រះកាយ និងព្រះលោហិតរបស់ព្រះជាម្ចាស់ ដូច្នេះអ្នកជឿទាំងអស់ត្រូវតែចងចាំការសុគតរបស់ព្រះយេស៊ូ។

## ខ. ព្រះបន្ទូលផ្តល់ជីវិតអស់កល្បជានិច្ច The Words of Eternal Life

គោលដៅទី៥. លើកបង្ហាញពីអ្វីដែលមនុស្សត្រូវធ្វើដើម្បីបានជីវិតអស់កល្ប។

សូមអាន យ៉ូហាន ៦:៦០-៧១។ មានអ្នកខ្លះនៅក្នុងចំណោមយើងដែលបានចាប់ផ្តើមដើរតាមព្រះយេស៊ូសព្វថ្ងៃនេះបានប្រព្រឹត្តខុស និងបែរចេញពីផ្លូវរបស់ព្រះអង្គ។ ព្រះយេស៊ូបានសួរទៅសាវ័ករបស់ព្រះអង្គថា តើពួកគេអាចនឹងបោះបង់ចោលព្រះអង្គដែលឬទេ? លោកពេត្រុសបានឆ្លើយតបថា "បពិត្រព្រះអម្ចាស់ តើអោយយើងខ្ញុំទៅរកនរណាវិញ? ព្រះបន្ទូលរបស់ព្រះអង្គផ្តល់ជីវិតអស់កល្បជានិច្ច" (ខ៦៣)។

ដើម្បីទទួលជីវិតអស់កល្បជានិច្ច យើងគួរតែស្គាល់ព្រះយេស៊ូ តែមិនគ្រាន់តែស្គាល់ព្រះអង្គនោះទេ។ មានមនុស្សជាច្រើនស្គាល់ព្រះយេស៊ូ ដោយមិនបានទទួលស្គាល់ព្រះអង្គជាព្រះសង្គ្រោះរបស់ពួកគេឡើយ។ ព្រះយេស៊ូបានអធិស្ឋានថា "រីឯជីវិតអស់កល្បជានិច្ចនោះ គឺអោយគេស្គាល់ព្រះអង្គ ដែលជាព្រះជាម្ចាស់ដ៏ពិតតែមួយគត់ និងអោយគេស្គាល់ព្រះយេស៊ូគ្រិស្ត ដែលព្រះអង្គចាត់អោយមក។" (យ៉ូហាន ១៧:៣)

តើអ្នកទទួលស្គាល់ព្រះយេស៊ូជាព្រះសង្គ្រោះផ្ទាល់របស់អ្នកដែលឬទេ? ប្រសិនបើមិនទាន់ទេ សូមអធិស្ឋានឥឡូវនេះ សារភាពអំពើបាបរបស់អ្នក ទៅចំពោះព្រះអង្គ និងសុំឱ្យព្រះជាម្ចាស់សង្គ្រោះអ្នក។ ក្តីសង្ឃឹមនៃការសង្គ្រោះរបស់អ្នកមិនមាននៅក្នុងការប្រព្រឹត្តរបស់អ្នកទេ ប៉ុន្តែ ជាអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់អ្នកវិញ។

លំហាត់អនុវត្តន៍

---

១៣ ចងចាំខគម្ពីរ យ៉ូហាន ១៧:៣។

១៤ តើអ្វីដែលអ្នកគួរតែធ្វើដើម្បីទទួលបានការសង្គ្រោះ?

ក) អ្នកគួរតែជឿថាព្រះយេស៊ូបានសុគតសម្រាប់អ្នក និងជឿលើព្រះអង្គជាព្រះសង្គ្រោះរបស់អ្នក។

ខ) អ្នកគួរតែទទួលស្គាល់ព្រះយេស៊ូ។

គ) អ្នកគួរតែទទួលបានពិន្ទុល្អនៅក្នុងមុខវិជ្ជានេះ។

## ច. ព្រះយេស៊ូ និងព្រះញាតិវង្សរបស់ព្រះអង្គ Jesus and His Brothers

គោលដៅទី៦. ពន្យល់ពីសារៈសំខាន់នៃការអត់ធ្មត់ក្នុងការដោះស្រាយជាមួយអ្នកដែលមិនជឿ។

សូមអាន យ៉ូហាន ៧:១-៩ បានកត់ត្រាពីគំនិតការយល់ឃើញផ្សេងៗគ្នារបស់មនុស្សអំពីព្រះយេស៊ូ។ មនុស្សមួយចំនួនមិនចង់ទទួលជឿលើព្រះយេស៊ូទេ។ មនុស្សខ្លះទៀតគំនិតរបស់ពួកគេងងឹតដោយសារតែគំនិតផ្ទាល់ខ្លួនរបស់ពួកគេ

មិនយល់ស្របជាមួយសេចក្ដីបង្រៀនរបស់ព្រះយេស៊ូ។ មានអ្នកខ្លះទៀតស្អប់ព្រះអង្គដោយសារតែទ្រង់បានបង្រៀនប្រឆាំងជាមួយអំពើបាប។

អំឡុងពេលនោះ បងប្អូនរបស់ព្រះយេស៊ូមិនបានជឿថា ទ្រង់គឺជាព្រះមេស្ស៊ីទេ។ តែក្រោយមកពួកគេបានជឿ។ ភាគច្រើននៃសត្រូវរបស់ព្រះយេស៊ូបានកែប្រែចិត្តបន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ។ ដូចគ្នានេះដែរ មនុស្សដែលជាសត្រូវនៃដំណឹងល្អភាគច្រើនបានកែប្រែចិត្តគំនិត និងជឿលើព្រះយេស៊ូ ប្រសិនបើយើងអធិស្ឋានសម្រាប់ពួកគេ។ ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់សិស្សរបស់ព្រះអង្គ ស្រឡាញ់ខ្មាំងសត្រូវរបស់ពួកគេ និងអធិស្ឋានសម្រាប់ពួកគេ។

## **ឆ. នៅពិធីបុណ្យបារាំ** At the Feast of Tabernacles

**គោលដៅទី៧. ពិពណ៌នាអាកប្បកិរិយាចំពោះយ៉ាងសំដៅទៅរកព្រះយេស៊ូ ហើយពន្យល់ពីសេចក្ដីបង្រៀនរបស់ព្រះយេស៊ូនៅក្នុងពិធីបុណ្យ។**

សូមអាន យ៉ូហាន ៧:១០-២៤។ មានខចំនួនប្រាំពីរដែលបានប្រាប់យើងថាព្រះយេស៊ូកំពុងតែស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់។ (សូមមើលនៅខ ១,១៣,១៩,២៥,៣០,៣២ និង៤៤) ទោះបីជាស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ក៏ដោយ ក៏ទ្រង់នៅតែបន្តការបង្រៀន និងបានយាងទៅក្រុងយេរូសាឡឹមដើម្បីចូលរួមពិធីបុណ្យសាសនានៅទីនោះដែរ។

សព្វថ្ងៃនេះ មានអ្នកដើរតាមព្រះយេស៊ូជាច្រើននាក់ដែលកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់នៅក្នុងប្រទេសមួយចំនួន ពីព្រោះគ្រិស្តបរិស័ទមិនត្រូវទទួលសិទ្ធពេញលេញ ឬ គឺជាការប្រឆាំងនឹងច្បាប់។ យើងគួរតែអធិស្ឋានសុំឱ្យព្រះជាម្ចាស់ប្រទានឱ្យពួកគេមានសេចក្ដីក្លាហានដើម្បីរក្សាការបង្រៀន ការអធិប្បាយ និងទីបន្ទាល់របស់ពួកគេ។

ការបង្រៀនរបស់ព្រះយេស៊ូធ្វើឱ្យមានការភ្ញាក់ផ្អើលដល់មេដឹកនាំមួយចំនួន។ ពួកគេបានដឹងថាព្រះយេស៊ូមិនបានចូលសាលារៀន ឬមានចំនេះដឹងខ្ពង់ខ្ពស់នោះទេ។ សេចក្ដីពិតដែលទ្រង់បានបង្រៀនគឺមកពីព្រះជាម្ចាស់។

នៅក្នុងខទី១៧បានបង្ហាញប្រាប់យើងថាប្រសិនបើយើងធ្វើតាមអ្វីដែលព្រះជាម្ចាស់ចង់ឱ្យយើងធ្វើ ទ្រង់នឹងបើកសម្ដែងឱ្យយើងយល់ពីសេចក្ដីពិត។ មានមនុស្សជាច្រើនដែលមិនបានជឿលើដំណឹងល្អគឺមិនអាចយល់ពីសេចក្ដីពិតឡើយ ពីព្រោះតែពួកគេមិនមិនមានឆន្ទះក្នុងការស្ដាប់បង្គាប់ព្រះជាម្ចាស់។ សូម្បីតែអ្នកខ្លះដែលមិនបានជឿថាព្រះជាម្ចាស់នៅអស់កល្បជានិច្ច និងទាក់ទងអ្នកដែលស្វែងរកទ្រង់នៅសព្វថ្ងៃនេះគឺតាមរយៈសេចក្ដីអធិស្ឋានដោយស្មោះអស់ពីចិត្ត។

**លំហាត់អនុវត្តន៍**

---

១៥ តើអ្នកធ្លាប់ស្គាល់មនុស្សដែលបដិសេធដំណឹងល្អដែរឬទេ?

១៦ តើបងប្អូនប្រុសស្រីទាំងអស់របស់អ្នកទទួលជឿលើព្រះយេស៊ូដែរឬទេ? សូមអធិស្ឋានសម្រាប់ពួកគេ។

មានមនុស្សខ្លះនៅតែមានការអ៊ូរទាំចំពោះការប្រោសឱ្យជារបស់ព្រះយេស៊ូនៅក្នុងថ្ងៃសប្ប័ទ។ ពេលខ្លះច្បាប់មួយហាក់បីដូចជាធ្វើឱ្យមានការប្រឆាំងនឹងអ្វីមួយទៀត។ នៅពេលដែលមានការនេះកើតឡើង ព្រះយេស៊ូបានបង្រៀនថា យើងគួរតែស្ដាប់បង្គាប់អ្វីដែលសំខាន់ជាងគេ។ ឧទាហរណ៍ ច្បាប់បានចែងថា មិនត្រូវធ្វើការងារនៅក្នុងថ្ងៃសប្ប័ទ និងបានចែងទៀតថាគ្រប់ក្មេងប្រុសទាំងអស់ត្រូវតែធ្វើពិធីកាត់ស្បែកនៅក្នុងថ្ងៃទីប្រាំបី។ ប្រសិនបើថ្ងៃទីប្រាំបីប៉ះចំថ្ងៃសប្ប័ទ មនុស្សត្រូវល្មើសនឹងច្បាប់ថ្ងៃសប្ប័ទហើយធ្វើតាមទំលាប់នៅក្នុងពិធីកាត់ស្បែកវិញ។ ព្រះយេស៊ូបានបង្រៀនថា ច្បាប់នៃការស្រឡាញ់ និងចិត្តសប្បុរស ប្រសើរជាជាងច្បាប់នៅក្នុងថ្ងៃសប្ប័ទទៅទៀត។

លំហាត់អនុវត្តន៍

---

១៧ ការបង្រៀនរបស់ព្រះយេស៊ូគឺពិតជាអស្ចារ្យដោយសាតែ
- ក) ទ្រង់បានចូលរៀននៅក្នុងសាលាដែលផ្ដល់ចំនេះដឹងខ្ពស់។
- ខ) បូជាចារ្យ ឬ ខណៈផារីស៊ីជាគ្រូបង្រៀនរបស់ព្រះអង្គ។
- គ) ការបង្រៀនរបស់ព្រះអង្គមកពីព្រះជាម្ចាស់។

១៨ ចូរអធិស្ឋានសម្រាប់មិត្តភក្តិដែលមិនទាន់បានការសង្គ្រោះ សុំឱ្យព្រះជាម្ចាស់ជួយពួកគេឱ្យមើលឃើញសេចក្ដីពិតនៃដំណឹងល្អ និងបំពីព្រះអង្គ។

១៩ សូមអធិស្ឋានសម្រាប់អស់អ្នកដែលកំពុងតែមានគ្រោះថ្នាក់ដោយសារតែដើរតាមព្រះយេស៊ូ។

## ង. តើទ្រង់គឺជាព្រះមេស្ស៊ី? Is He the Messiah?

**គោលដៅទី៨. ពន្យល់ពីហេតុផលដែលព្រះយេស៊ូនៅតែបន្តព័ន្ធកិច្ចរបស់ព្រះអង្គទោះបីជាព្រះអង្គមានសត្រូវក៏ដោយ។**

សូមអាន យ៉ូហាន ៧:២៥-៣១។ ហ្វូងមនុស្សមានការភ្ញាក់ផ្អើលនៅពេលដែលគេបានឃើញការបង្រៀនរបស់ព្រះយេស៊ូនៅក្នុងព្រះវិហារពីព្រោះគេបានដឹងច្បាស់ថាពួកមេដឹកនាំសាសនាកំពុងតែព្យាយាមសម្លាប់ព្រះអង្គ។ ប៉ុន្តែ ពួកមេដឹកនាំនោះមិនអាចសម្លាប់ព្រះអង្គបានឡើយពីព្រោះពេលវេលារបស់ព្រះអង្គមិនទាន់មកដល់នោះទេ។ ព្រះយេស៊ូបានដឹងថាព្រះជាម្ចាស់បានបញ្ជូនព្រះអង្គឱ្យមក ហើយព្រះជម្ចាស់នឹងជួយព្រះអង្គក្នុងការបញ្ចប់កិច្ចការរបស់ព្រះអង្គ។ ដូច្នេះហើយបានជាទ្រង់នៅតែបន្តការបង្រៀនរបស់ព្រះអង្គនៅក្នុងព្រះវិហារ។ ព្រះយេស៊ូបានដឹងថាព្រះបន្ទូលរបស់ព្រះអង្គជះឥទ្ធិពលទៅលើអស់អ្នកដែលបានបើកចិត្តទទួលព្រះអង្គ។ តាមរយៈការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះបិតា មនុស្សអាចនឹង

បន្តការជឿរបស់ពួកគេទៅលើព្រះអង្គ ដោយចូលមកទទួលបទពិសោធន៍នៃជីវិតអស់កល្បជានិច្ច និងជីវិតពេញបរិបូណ៌ ដែលព្រះអង្គបានសន្យាទុក។

**លំហាត់អនុវត្តន៍**

---

២០ តើពួកមេដឹកនាំចង់ធ្វើអ្វីចំពោះព្រះយេស៊ូ?

.......................................................................................................................................................

២១ តើនរណាជាអ្នកបញ្ជូនព្រះយេស៊ូមក?

.......................................................................................................................................................

២២ តើវាតែងតែងាយស្រួលមែនទេក្នុងការធ្វើតាមអ្វីដែលព្រះជាម្ចាស់ចង់ឱ្យអ្នកធ្វើ?

.......................................................................................................................................................

២៣ តើនរណានឹងនៅតែថែរក្សាអ្នក ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ?

.......................................................................................................................................................

## គេចាត់កងរក្សាព្រះវិហារអោយមកចាប់ព្រះយេស៊ូ Guards Sent to Arrest Jesus

សូមអានយ៉ូហាន ៧:៣២-៣៦។ ជាការពិតមានមនុស្សជាច្រើនកំពុងតែជឿលើព្រះយេស៊ូ ហើយបានធ្វើឱ្យពួកអ្នកខាងគណៈផារីស៊ីស្ទើរតែទាំងអស់បានឃុបឃិតគ្នាដើម្បីសម្លាប់ព្រះអង្គ។ ព្រះយេស៊ូបានដឹងពីបំណងចិត្តរបស់ពួកគេ ហើយព្រះអង្គក៏បានដឹងទៀតថាទ្រង់ត្រូវយាងមកផែនដីគឺដើម្បីសុគតជំនួសអំពើបាបរបស់យើង។ ក្នុងការសម្តែងអំពីការសុគតរបស់ព្រះអង្គ ព្រះយេស៊ូបានមានព្រះបន្ទូលអំពីកន្លែងដែលទ្រង់នឹងទៅ ប៉ុន្តែពួកគេមិនអាចដើរតាមព្រះអង្គបានឡើយ។ បន្ទាប់មក កិច្ចការរបស់ព្រះអង្គនឹងត្រូវបាបញ្ចប់។ ទ្រង់នឹងយាងត្រឡប់ទៅនគរស្ថានសួគ៌ជាមួយព្រះបិតារបស់ព្រះអង្គវិញ ហើយអស់អ្នកដែលបានដើរតាមព្រះយេស៊ូនឹងបានទៅនៅជាមួយព្រះអង្គនៅក្នុងសិរីរុងរឿងរបស់ព្រះអង្គនៅពេលដែលពួកគេស្លាប់ទៅ។

លំហាត់អនុវត្តន៍

២៤ តើយើងដឹងថាព្រះយេស៊ូមានសត្រូវបានដោយរបៀបណា?

ក) នាយកបូជាចារ្យចង់សម្លាប់ព្រះអង្គ។

ខ) អភិបាលចក្រភពរ៉ូមបានបញ្ជូនគេមកចាប់ព្រះអង្គ។

គ) បណ្តាជនទាំងអស់ចង់សម្លាប់ព្រះអង្គ។

**ទន្លេដែលមានទឹកផ្តល់ជីវិត** Streams of Living Water

ព្រះយេស៊ូមានព្រះបន្ទូលថា "អ្នកណាស្រេកទឹក សុំអញ្ជើញមករកខ្ញុំ ហើយពិសាចុះ" (យ៉ូហាន ៧:៣៧)។ ពួកយើងបានរៀនរួចមកហើយថាព្រះយេស៊ូបានប្រៀបធៀបការសង្គ្រោះទៅនឹងទឹកនៃជីវិត។ នៅក្នុងខទី២៩ បានបញ្ជាក់យ៉ាងច្បាស់ថាទឹកនៅត្រង់នេះគឺប្រៀបបាននឹងព្រះវិញ្ញាណដ៏វិសុទ្ធដែលនឹងប្រទានដល់អស់អ្នកដែលជឿបន្ទាប់ពីពួកគេទទួលបានការសង្គ្រោះ។ បន្ទាប់ពីនរណាម្នាក់ បានទទួលជឿលើព្រះសង្គ្រោះ បុគ្គលម្នាក់នោះគួរតែមានបំណងចិត្តចង់បានការបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងកណ្ឌគម្ពីរកិច្ចការ យើងមើលឃើញថាអស់អ្នកដែលជឿបានបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធបន្ទាប់ពីបទពិសោធន៍នៃការសង្គ្រោះរបស់ពួកគេ។

លំហាត់អនុវត្តន៍

២៥ នៅពេលដែលព្រះយេស៊ូមានព្រះបន្ទូលថា "អ្នកណាស្រេកទឹក សុំអញ្ជើញមករកខ្ញុំ ហើយពិសាចុះ" គឺទ្រង់ចង់មានព្រះបន្ទូលអំពី៖

ក) ការសង្គ្រោះ ដែលទ្រង់ហៅថាជាទឹកផ្តល់ជីវិត។

ខ) ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកដែលផ្តល់ឱ្យអ្នកជឿទាំងអស់បន្ទាប់ពីពួកគេទទួលបានការសង្គ្រោះ។

គ) ទឹកបានមកពីទន្លេយ័រដាន់។

## ឈ. ការខ្វែងគំនិតរបស់បណ្តាជន Division Among the People

គោលដៅទី៩. កំណត់ពីរបៀបដែលព្រះយេស៊ូបានបំពេញតាមទំនាយអំពីព្រះមេស្ស៊ី។

សូមអាន យ៉ូហាន ៧:៤០-៤៤។ មនុស្សមានគំនិត និងការយល់ឃើញផ្សេងៗពីគ្នាអំពីព្រះយេស៊ូរហូតមកទល់សព្វថ្ងៃនេះ។ អស់អ្នកដែលគិតថាទ្រង់គឺជា ព្យាការីដែលមកតាមការសន្យារបស់ព្រះជាម្ចាស់ ជាព្រះមេស្ស៊ី និងជាព្រះបុត្រារបស់ព្រះជាម្ចាស់អ្នក ទាំងនោះ គឺគិតបានត្រឹមត្រូវ។

ព្រះយេស៊ូបានរស់នៅភូមិមួយនៃស្រុកកាលីឡេ ប៉ុន្តែទ្រង់បានកើតនៅភូមិបេថ្លេហិម។ លោកលូកា និងលោកម៉ាថាយទាំងពីរនាក់មានជាប់ខ្សែស្រឡាយជាមួយព្រះយេស៊ូ ដែលបានបង្ហាញថាទ្រង់ជាញាតិវង្សរបស់ព្រះបាទដាវីឌ។ ទ្រង់បានសម្រេចទំនាយដែលបានទាយអំពីព្រះមេស្ស៊ី។

**លំហាត់អនុវត្តន៍**

---

២៦ តើនៅកន្លែងណាដែលមនុស្សនិយាយថាព្រះមេស្ស៊ីនឹងប្រសូត?

.......................................................................................................................................................

២៧ តើព្រះយេស៊ូប្រសូតនៅកន្លែងណា?

.......................................................................................................................................................

២៨ តើព្រះយេស៊ូជាញាតិវង្សរបស់ព្រះដាវីឌមែនដែលឬទេ?

.......................................................................................................................................................

## ពួកអ្នកដឹកនាំសាសនាមិនជឿលើព្រះអង្គ Unbelief of the Religious Leaders

សូមអាន យ៉ូហាន ៧:៤៥-៥២។ ពួកគណៈផារីស៊ីចង់ឱ្យគេមកចាប់ព្រះយេស៊ូ ជាពិសេសចាប់តាំងពីកងរក្សាព្រះវិហារបានសារភាពថា "ពុំដែលមាននរណានិយាយដូចលោកនោះឡើយ" គ្មាននរណាម្នាក់អាចនិយាយដូចជាព្រះយេស៊ូនោះទេពីព្រោះទ្រង់គឺជាព្រះជាម្ចាស់នៅក្នុងសណ្ឋានជាមនុស្ស។ យើងគួរតែរៀនអំពីអ្វីដែលព្រះយេស៊ូមានព្រះបន្ទូលពីទិដ្ឋភាពជាច្រើននៅក្នុងជីវិត និងទុកការបង្រៀនរបស់ព្រះអង្គដែលលើសពីអ្វីដែលមនុស្សផ្សេងទៀតបាននិយាយ។ អ្នកដឹកនាំសាសនាមានឱកាសដើម្បីទទួលជឿលើសេចក្តីពិតនេះ ប៉ុន្តែ ពួកគេបានបដិសេធមិនទទួល។

**លំហាត់អនុវត្តន៍**

---

២៩ តើទីបន្ទាល់អ្វីដែលកងរក្សាព្រះវិហារបាននិយាយអំពីព្រះយេស៊ូ?

ក) "ពុំដែលមាននរណានិយាយដូចលោកនោះឡើយ"។

ខ) "គ្មានព្យាការីធ្លាប់មកពីស្រុកកាលីឡេឡើយ"។

គ) តើបុរសនេះបានដឹងច្រើនដូចម្តេចបានបើគាត់មិនដែលធ្លាប់ទៅសាលារៀនផង។

## សូមផ្ទៀងចម្លើយរបស់អ្នក

១ ខ) គាត់ចង់ប្រោសឱ្យជា

៤ គ) ស្រឡាញ់អ្នកដូចជាព្រះបិតារបស់អ្នកដែលគង់នៅស្ថានបរមសុខ។

២ គ) ព្រះយេស៊ូបានប្រោសបុរសពិកានៅក្នុងថ្ងៃសប្ប័ទ

១១ គ) មនុស្សទាំងអស់ត្រូវតែទទួលយកព្រះអង្គមកដាក់នៅក្នុងជីវិតរបស់ពួកគេដូចជាគេបរិភោគអាហារសម្រាប់បំពេញរូបកាយរបស់គេដែរ

៦ គ) ទ្រង់បានធ្វើឱ្យមានអាហារបរិភោគគ្រប់គ្រាន់សម្រាប់មនុស្ស ៥០០០នាក់។

១២ គ) តំណាងឱ្យព្រះកាយ និងព្រះលោហិតរបស់ព្រះជាម្ចាស់ ដូច្នេះអ្នកជឿទាំងអស់ចងចាំការសុគតរបស់ព្រះយេស៊ូ

៧ ខ) អភិសេកព្រះយេស៊ូជាស្តេចនៅលើប្រទេសរបស់ពួកគេ

៩ ខ) ក្រុងកាពើណិម នៃឆ្នេរសមុទ្រនៃស្រុកកាឡីលេ

១៤ ក) អ្នកគួរតែជឿថាព្រះយេស៊ូបានសុគតសម្រាប់អ្នក និងជឿលើព្រះអង្គជាព្រះសង្គ្រោះរបស់អ្នក

២៤ ក) នាយកបូជាចារ្យចង់សម្លាប់ព្រះអង្គ

១៧ គ) ការបង្រៀនរបស់ព្រះអង្គមកពីព្រះជាម្ចាស់

២៥ ខ) ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកដែលផ្តល់ឱ្យអ្នកជឿទាំងអស់បន្ទាប់ពីពួកគេទទួលបានការសង្គ្រោះ

២០ សម្លាប់ព្រះអង្គ

២៦ បេថ្លេហិម

២១ ព្រះជាម្ចាស់

២៧ បេថ្លេហិម

២២ អត់ទេ

២៨ មែន

២៣ ព្រះជាម្ចាស់

២៩ ក) "ពុំដែលមាននរណានិយាយដូចលោកនោះឡើយ"